**ប្រការ ៣ :** ស្ថានីយ៍ដាំឈើនេះ ជាផ្នែកមួយស្ថិតនៅក្រោមការគ្រប់គ្រង របស់ការិយាល័យដាំឈើនៃនាយកដ្ឋានរុក្ខាប្រមាញ់ ។

**ប្រការ ៤ :** ស្ថានីយ៍ដាំឈើគ្រប់គ្រងដោយប្រធានមួយរូប អនុប្រធានមួយរូបជាជំនួយការ ។

**ប្រការ ៥ :** អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាន ផែនការ ស្ថិតិ និង ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**តាវ សេងហួរ**

* * *

## ៤— ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

## ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៦៦៤ អយក.ប្រ.ក**

**ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា**

**សម្តេច ហ៊ុន សែន សិរីសន្ធាយ**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

– បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញ ព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១ –១១–៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

– បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃ គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–៩៤ ។

- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០-១១-៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ។
- បានពិនិត្យលិខិតស្នើសុំរបស់គណៈកម្មការសាងសង់ សាលាបឋមសិក្សាសិរីសន្ធាយ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៨៦ ដោយមានចំណារឯកភាពពីឯកឧត្តម **យុន្ធ តូចខន** អភិបាលរងទី ១ ខេត្ត ព្រៃវែងលេខ ១០០-៨៦ ចុះថ្ងៃទី ២២ ឧសភា ១៩៨៦ ។
- យោងតាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡាខេត្ត ព្រៃវែង ប្តូរឈ្មោះសាលាបឋមសិក្សាសិរីសន្ធាយ នៅភូមិសិរីសន្ធាយ ឃុំបាយ ស្រុកបាភ្នំ ខេត្ត ព្រៃវែង មកជា «សាលាបឋមសិក្សា **ហ៊ុន សែន សិរីសន្ធាយ** » វិញ ចាប់ពីឆ្នាំសិក្សា១៩៨៥-៨៦ នេះតទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : មន្ទីរក្រសួងអប់រំយុវជន និង កីឡា នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ចនាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំ យុវជន និង កីឡាខេត្តព្រៃវែងការិយាល័យអប់រំយុវជន និងកីឡា ស្រុកបាភ្នំ នាយកសាលាបឋមសិក្សា **ហ៊ុន សែន សិរីសន្ធាយ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**គា សាមាន**

* * *